# សមាជិកសភាអាស៊ាន និងអឺរ៉ុប អំពាវនាវឲ្យមានការដោះលែងអ្នកទោសមនសិការជាបន្ទាន់

ទីក្រុងបាងកក ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ សមាជិកសភាអឺរ៉ុប និង សភាជុំវិញតំបន់អាស៊ីអាគ្នេយ៍ជិត១០០នាក់ បានផ្ញើលិខិតចំហទៅកាន់រដ្ឋមន្ត្រីការបរទេសសហភាពអឺរ៉ុប និងអាស៊ាន នៅថ្ងៃនេះ ទាមទារឲ្យពួកគេចាត់វិធានការជាបន្ទាន់ ដើម្បីធានាឲ្យមានការដោះលែងអ្នកទោសមនសិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍នេះ។

សមាជិកសភាទាំងអស់បានសរសេរថា "ការដោះលែងអ្នកទោសមនសិការទាំងអស់ នឹងផ្ញើសារដ៏មានឥទ្ធិពលមួយអំពីការប្តេជ្ញាចិត្តរួមគ្នានៃបណ្តារដ្ឋាភិបាល នៅអឺរ៉ុប និងអាស៊ីអាគ្នេយ៍ ដើម្បីការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស និងជាការធានាថា កិច្ចសហប្រតិបត្តិការរបស់ពួកយើងទទួលបាននូវអត្ថប្រយោជន៍ប្រកបដោយនិរន្តរភាព និងទូលំទូលាយ សម្រាប់ប្រជាពលរដ្ឋរបស់យើង។"

លិខិតដែលត្រូវបានចុះហត្ថលេខាដោយតំណាងចំនួន៩៣នាក់ មកពី២២ប្រទេស ធ្វើឡើងនៅមុនថ្ងៃនៃកិច្ចប្រជុំរដ្ឋមន្ត្រីអឺរ៉ុប-អាស៊ាន លើកទី២១ នៅក្នុងទីក្រុងបាងកក ប្រទេសថៃ ដែលរដ្ឋមន្ត្រីការបរទេសមកពីរដ្ឋជាសមាជិកសហភាពអឺរ៉ុប និងអាស៊ាន នឹងជួបពិភាក្សាអំពីបញ្ហានានា ដែលជាផ្នែកនៃកិច្ចខិតខំប្រឹងប្រែងក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងតំបន់ទាំងពីរ។ សមាជិកសភាលើកឡើងថា កិច្ចជំនួបដែលមានរយៈពេល២ឆ្នាំម្តងនេះ ផ្តល់នូវឱកាសសម្រាប់មេដឹកនាំមកពីតំបន់ទាំងពីរ ដើម្បីបង្ហាញនូវការប្តេជ្ញាចិត្តរបស់ពួកគេ ក្នុងការគាំទ្រសិទ្ធិមនុស្សជាសកល។

លិខិតចំហនេះបានសរសេរថា "ក្នុងនាមជាអ្នកតំណាងដែលជាប់ឆ្នោត វាគឺជាតួនាទីរបស់យើងដើម្បីធានាថា សម្លេងប្រជាពលរដ្ឋរបស់យើងត្រូវបានយកចិត្តទុកដាក់ដោយមេដឹកនាំនៃប្រទេសជាតិរបស់យើង។ នៅក្នុងតួនាទីនេះ យើងសូមជម្រុញឲ្យអ្នក គោរពនូវការសន្យាពីមុនៗរបស់អ្នក និងមានចំណាត់ការបន្ទាន់ដើម្បីធានាឲ្យមានការដោះលែងអ្នកដែលត្រូវបានឃុំខ្លួន ដោយសារការសម្តែងចេញនូវជំនឿនយោបាយ ឬសាសនារបស់ពួកគេ ហើយចាត់វិធានការដោយសន្តិវិធី ក្នុងការគាំទ្រនូវជំនឿទាំងនោះ។

នៅក្នុងលិខិតចំហនេះ សមាជិកសភាក៏បានលើកឡើងអំពី សំណុំរឿងដែលមានការចាប់អារម្មណ៍ច្រើនមួយចំនួន នៃអ្នកទោសមនសិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមមាន អតីតមេដឹកនាំគណបក្សប្រឆាំងម៉ាឡេស៊ី Anwar Ibrahim មេធាវីសិទ្ធិមនុស្សវៀតណាម Nguyen Van Dai និងបុគ្គលិកសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (អាដហុក) ដែលជាអង្គការមិនមែនរដ្ឋាភិបាលដ៏សំខាន់មួយ។ ករណីដែលត្រូវបានបញ្ចូលនៅក្នុងលិខិតនេះ គឺមិនតំណាងឲ្យបញ្ជីឈ្មោះលម្អិតនៃអ្នកទោសមនសិការនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ទាំងអស់នោះទេ ប៉ុន្តែគ្រាន់ជាឧទាហរណ៍មួយចំនួនបង្ហាញពីករណីផ្សេងៗគ្នាជាច្រើន នៅទូទាំងប្លុកនៃប្រទេសជាសមាជិកទាំង១០ក្នុងតំបន់។

សមាជិកសភាបានថ្លែងថា មានភាពចាំបាច់ជាបន្ទាន់សម្រាប់បណ្តារដ្ឋាភិបាលនៃតំបន់អ៊ឺរ៉ុប និង អាស៊ីអាគ្នេយ៍ ក្នុងការផ្តល់ការគាំទ្រចំពោះការប្តេជ្ញាចិត្តវោហាសាស្ត្ររបស់ខ្លួន តាមរយៈសកម្មភាពជាក់លាក់ រួមមាន ការដោះលែងអ្នកទោសមនសិការ ជាបន្ទាន់ និងឥតលក្ខខណ្ឌ។

ឯកឧត្តមសមាជិកសភាម៉ាឡេស៊ី Charles Santiago ប្រធានអង្គការសមាជិកសភាអាស៊ានដើម្បីសិទ្ធិមនុស្ស និងជាហត្ថលេខីនៃលិខិតចំហនេះ បានថ្លែងថា "ជាច្រើនដងហើយ យើងបានស្តាប់អ្នកការទូត និងមន្ត្រីមកពីអាស៊ាន និងរដ្ឋាភិបាលអន្តរជាតិ សន្យាជួយលើកកម្ពស់សិទ្ធិមនុស្សក្នុងតំបន់ ខណៈពេលធ្វើសេចក្តីថ្លែងការណ៍នៅក្នុងវេទិកាទ្វេភាគី ឬពហុភាគី។ ប៉ុន្តែតាមស្ថានភាពជាក់ស្តែង មានការអនុវត្តតិចតួចប៉ុណ្ណោះ ដែលកើតចេញពីកិច្ចពិភាក្សាទាំងនេះ។"

"ប៉ុន្តែកិច្ចប្រជុំរដ្ឋមន្ត្រីអ៊ឺរ៉ុប-អាស៊ាន នាពេលខាងមុខនេះ មិនធម្មតាដូចសព្វរាល់ដងនោះទេ។ ប្រសិនបើអាចទទួលបាននូវការដោះលែងអ្នកទោសមនសិការ បណ្តាមេដឹកនាំអាចមានឱកាសនឹងចាកចេញទីក្រុងបាងកក ដោយបង្ហាញថា ពួកគេបានធ្វើអ្វីដែលពួកគេនិយាយ នៅពេលដែលពួកគេនិយាយអំពីសិទ្ធិ។"

នៅពេលបណ្តាមេដឹកនាំអាស៊ានបានជួបជាមួយលោកប្រធានាធិបតី **បារ៉ាក់ អូបាម៉ា** នៅឯសហរដ្ឋអាមេរិក កាលពីដើមឆ្នាំនេះ សេចក្តីប្រកាសរួមរបស់ពួកគេបានបញ្ជាក់បង្ហាញពីការប្តេជ្ញាចិត្តរួម "ដើម្បីពង្រឹងលទ្ធិប្រជាធិបតេយ្យ ជម្រុញឲ្យមានអភិបាលកិច្ចល្អ និងប្រកាន់ខ្ជាប់នូវនីតិរដ្ឋ លើកកម្ពស់ និងការពារសិទ្ធិមនុស្ស និងសេរីភាពចម្បងៗ។" ធម្មនុញ្ញអាស៊ានក៏បានចែងនូវគោលការណ៍រួមរបស់រដ្ឋជាសមាជិក ស្តីពីការគោរពសេរីភាពចម្បងៗ និងការប្រកាន់ខ្ជាប់នូវគោលការណ៍អភិបាលកិច្ចបែបប្រជាធិបតេយ្យ។

ទោះជាមានការប្តេជ្ញាចិត្តទាំងនេះយ៉ាងណាក៏ដោយ តំបន់អាស៊ានបានឃើញនូវភាពកាន់តែរួមតូចនៃលំហសម្រាប់សង្គមស៊ីវិល និងភាពអន់ថយនៃបទដ្ឋានលទ្ធិប្រជាធិបតេយ្យ និងការការពារសិទ្ធិមនុស្ស។ ក្នុងរយៈពេលបីឆ្នាំកន្លងទៅនេះ តំបន់អាស៊ានបានឃើញពីការដណ្តើមអំណាចដោយកម្លាំងយោធានៅក្នុងប្រទេសថៃ ការកើនឡើងនូវការវាយប្រហារដែលគាំទ្រដោយរដ្ឋាភិបាលទៅលើអ្នកនយោបាយគណបក្សប្រឆាំង និងសង្គមស៊ីវិល នៅក្នុងប្រទេសកម្ពុជា និងម៉ាឡេស៊ី និង "សង្គ្រាមប្រឆាំងគ្រឿងញៀន" ដែលបានបង្កឲ្យមានការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការធ្លាក់ចុះនៃនីតិរដ្ឋនៅក្នុងប្រទេសហ្វីលីពីន។ ទន្ទឹមនឹងនេះ ប្រទេសដូចជា ឡាវ និង វៀតណាម បានកសាងប្រព័ន្ធនយោបាយផ្តាច់ការរបស់ខ្លួនកាន់តែរឹងមាំ និងកាន់តែរឹតត្បិតលំហប្រជាពលរដ្ឋ។

លោកជំទាវ មូរ សុខហួរ សមាជិកសភានៃប្រទេសកម្ពុជា និងជាហត្ថលេខីនៃលិខិតចំហនេះ បានថ្លែងថា "ការដើរថយក្រោយនៃតំបន់បង្កឲ្យមានការព្រួយបារម្ភជាថ្មី។ សម្លេងអ្នកឯករាជ្យគ្រប់ប្រភេទកំពុងក្លាយជាមុខសញ្ញាគោលដៅ ដែលមានទាំងពីសកម្មជនសិទ្ធិដីធ្លី ទៅអ្នកសរសេរប្លុក ទៅកម្មកររោងចក្រ។ សូម្បីតែសមាជិកសភាក៏មិនមានសុវត្ថិភាពពីការធ្វើទុកបុកម្នេញ និងការចាប់ខ្លួនផងដែរ។ សហភាពអ៊ឺរ៉ុប អាចជាដៃគូដ៏សំខាន់ ក្នុងការធ្វើការប្រឆាំងនឹងនិន្នាការអវិជ្ជមាននេះ ហើយយើងរីករាយដែលទទួលបានការគាំទ្រពីសមាជិកជាច្រើននៃសភាអ៊ឺរ៉ុប នៅក្នុងការអំពាវនាវឲ្យមានការដោះលែងអ្នកទោសមនសិការនេះ។"

អឺរ៉ុបតំណាងឲ្យដៃគូពាណិជ្ជកម្មធំជាងគេទី៣របស់អាស៊ាន ហើយសហភាពអឺរ៉ុបបានផ្តួចផ្តើមការចរចាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយរដ្ឋជាសមាជិកអាស៊ានយ៉ាងតិចចំនួន៦។ សហភាពអឺរ៉ុបក៏ជាវិនិយោគិនខាងក្រៅដែលធំជាងគេនៅក្នុងបណ្តាប្រទេសអាស៊ាន ស្មើនឹងចំនួនដែលលើសពីមួយភាគប្រាំនៃការវិនិយោគផ្ទាល់ពីបរទេសសរុបពីខាងក្រៅតំបន់។

ឯកឧត្តម Santiago បានថ្លែងថា "ការទទួលខុសត្រូវចុងក្រោយគឺស្ថិតនៅលើរដ្ឋាភិបាលរបស់ពួកគេផ្ទាល់ ដែលត្រូវគោរពសិទ្ធិពលរដ្ឋរបស់ពួកគេ។ ប៉ុន្តែរដ្ឋាភិបាលអឺរ៉ុបក៏ត្រូវបង្កើន និងប្រើប្រាស់នូវឥទ្ធិពលសេដ្ឋកិច្ច និងនយោបាយដែលមានសារៈសំខាន់របស់ពួកគេ ដើម្បីជម្រុញឲ្យមានការផ្លាស់ប្តូរ។"

"យើងសង្ឃឹមនឹងឃើញថា ទំនាក់ទំនងអឺរ៉ុប-អាស៊ាន ត្រូវបានពង្រឹងតាមវិធីដែលផ្តល់អត្ថប្រយោជន៍ដល់ប្រជាពលរដ្ឋនៅលើទ្វីបទាំងពីរ។ កិច្ចព្រមព្រៀងនយោបាយត្រូវបញ្ចូលនូវខច្បាប់ដាក់លក្ខខណ្ឌស្តីពីសិទ្ធិមនុស្ស ហើយកិច្ចព្រមព្រៀងពាណិជ្ជកម្មត្រូវចរចាក្នុងវិធីដែលការពារសិទ្ធិសហគមន៍ដែលងាយរងគ្រោះ និងលើកកម្ពស់អត្ថប្រយោជន៍យ៉ាងទូលំទូលាយ។"